# វិធីសាស្ត្រតាក់តែងលិខិតបទដ្ឋានគតិយុត្ត
# កំណត់សម្គាល់ទី១ អំពីមូលបទនៃអនុក្រឹត្យ

## ១.សេចក្តីផ្តើម

ក្នុងអនុក្រឹត្យ ក្រៅពីចំណងជើង ផ្នែកបន្ទាប់គឺមូលបទ (ឯកសារយោង)។ នៅមានបញ្ហាមិនច្បាស់លាស់មួយចំនួន ដោយសារតែមិនទាន់មានការណែនាំលម្អិត ដូចនេះ មានសំណួរមួយចំនួន អាចត្រូវសួរថាតើត្រូវសរសេរប្រភេទឯកសារអ្វីទៅក្នុងមូលបទនិងថាតើគួរដាក់ប្រភេទឯកសារណាមុនឬដាក់ក្រោយជាដើម?

អត្ថបទនឹងពិនិត្យមើលអនុក្រឹត្យមួយចំនួន ព្យាយាមបង្ហាញអំពីរបៀបសរសេរមូលបទនិងទាញសេចក្តីសន្និដ្ឋានជាបឋម។

## ២. ខ្លឹមសារ

តាមការកត់សម្គាល់ មានឯកសារយ៉ាងតិចពីរប្រភេទដែលត្រូវដាក់បញ្ចូលៈ ទី១ ដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវតែដាក់ចូលជាចាំបាច់ រីឯកសារមួយចំនួន ដាក់បញ្ចូលឬមិន វាអាស្រ័យលើភាពចាំបាច់និងភាពពាក់ព័ន្ធ។ ឯកសារដែលចាំបាច់គឺឯកសារបង្កើតក្រសួង និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង (ករណីសេចក្តីព្រាងអនុក្រឹត្យ មិនមែនជាអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ) ច្បាប់សារធាតុពាក់ព័ន្ធ ដែលជាមូលដ្ឋាន ឬចង្អុលឲ្យបង្កើតអនុក្រឹត្យ ប្រសិនបើលិខិតបទដ្ឋានគតិយុត្តដែលនឹងរៀបចំពាក់ព័ន្ធឬស្នើឡើងដោយក្រសួងសាមី។ អនុក្រឹត្យខ្លះពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងពីរឬបី ដូចនេះ យើងក៏ត្រូវយោងដល់ច្បាប់បង្កើតក្រសួងទាំងនោះផងដែរ។ ទោះបីជាយ៉ាងនេះក្តី ចំនួនឯកសារត្រូវដាក់បញ្ចូលមិនគួរច្រើនលើសលុបពេកទេ។ ជាតថាភាព ប្រសិនបើដាក់ចូលច្រើនពេក វាទំនងនឹងមិនសាកសម ខណៈករណីខ្លះ ឯកសារយោងច្រើន ក៏ប៉ុន្តែខ្លឹមសារនៃអនុក្រឹត្យខ្លីពេក។ បន្ថែមពីលើនេះ ឯកសារដែលយោង មិនអាចទាបជាងអនុក្រឹត្យទេ[1]។ គោល

[1] ទីស្តីការគណៈរដ្ឋមន្ត្រី ស.រ.លេខ០៣ គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត, ឆ្នាំ២០១៣, ទំ.៧០ (ស.រ.លេខ០៣)។

ការណ៍ណែនាំ បានសរសេរថា គេអាចយោងដល់កិច្ចព្រមព្រៀងឬអនុសញ្ញាអន្តរជាតិផងដែរក្នុងមូលបទនៃអនុក្រឹត្យ[2]។

ពាក់ព័ន្ធនឹងការដាក់មុនឬក៏ក្រោយ (ឋានានុក្រមនៃឯកសារ) មានការឯកភាពហើយ អំពីឯកសារបីដែលត្រូវដាក់លើគេ ផ្តើមពីរដ្ឋធម្មនុញ្ញ ប៉ុន្តែបន្តបន្ទាប់មកទៀត ជាឯកសារអ្វី? អ្នកតាក់តែងខ្លះ ស្នើថាត្រូវដាក់ឯកសារច្បាប់បង្កើតក្រសួងសំខាន់មុនគេ។ នេះជាការលំបាក ពីព្រោះមិនមានការវាស់កំណត់ជាក់លាក់ថា ក្រសួងណាសំខាន់ជាង។ អ្វីដែលបានឯកភាពគឺថា ច្បាប់ស្តីពីការបង្កើតអង្គការ ឬរចនាសម្ព័ន្ធ (Organic Laws) (ដូចជាច្បាប់បង្កើតក្រសួង) ត្រូវដាក់មុន(លើ)ច្បាប់សារធាតុ។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាតឆ្នាំ២០១៩ ផ្តួចផ្តើមដោយក្រសួងរ៉ែនិងថាមពល ត្រូវដាក់ក្រោមច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល។ ទំនងជាឈរលើគោលការណ៍នេះហើយ ដែលគេឯកភាពគ្នាដាក់ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅលើ ព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ទោះបីតាមឋានានុក្រម ព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ ខ្ពស់ជាងព្រះរាជក្រឹត្យតែងតាំងសមាសភាព។ នេះទំនងជាករណីលើកលែងមួយ។

ក្នុងមូលបទខ្លះ មានយោងអនុក្រឹត្យជាច្រើន មានថ្មី ឬមានកាលបរិច្ឆេទចាស់។ អ្នកតាក់តែងខ្លះ អះអាងថា ត្រូវដាក់មុននូវឯកសារមានកាលបរិច្ឆេទថ្មីៗ។ ទោះបីជាយ៉ាងណាក្តី អ្នកខ្លះ ស្នើថាត្រូវដាក់អនុក្រឹត្យមេ[3]មុនគេបន្ទាប់ពីច្បាប់។

សម្រាប់បច្ចេកទេសនៃការសរសេរ វាមានភាពស្មុគ្រស្មាញ និងសរសេរច្រើនបែប ក៏ប៉ុន្តែ ក្រុមប្រឹក្សាអ្នកច្បាប់បានសម្រេចលុប "០" សរសេរនៅមុខលេខ ដូចជាលេខ "០៦"នៃកាលបរិច្ឆេទ ក្នុងចំណងជើងនៃលិខិតបទដ្ឋានគតិយុត្តដាក់ក្នុងមូលបទ។ ឯកសារនៅត្រៃចុងក្រោយ នៃមូលបទមានជម្រើសសរសេរពារបៀប ដែលមានចែងក្នុងគោលការណ៍ណែនាំរួចហើយ ដែលអ្នកតាក់តែងត្រូវតែគោរព ដើម្បីសង្គត់ភាព៖ ១. យោងតាមសំណើរបស់ក្រសួង...ឬ ២. យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ឬ ៣. បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី...ខែ..[4]។ មានការអះអាងថា ក្នុងនីតិកាលទី៧នៃរដ្ឋសភា (២០២៣) រាជរដ្ឋាភិបាលបាន សម្រេចឲ្យយកជម្រើសទីបីក្នុងគ្រប់ករណីទាំងអស់ (មិនទាន់ជាលាយលក្ខណ៍អក្សរ)។

---

[2] ស.រ.លេខ០៣ លេខយោងទី១ខាងលើ,ទំ.៦៩។

[3] មិនមានការកំណត់និយមន័យទេ។

[4] ស.រ.លេខ០៣ ស.រ.លេខ០៣ លេខយោងទី១ខាងលើ,ទំ.៧២។

## ៣. សង្ខេប

ក្នុងមូលបទការសម្រេចដាក់ឯកសារប្រភេទណាចូល គេត្រូវពិចារណានូវភាពពាក់ព័ន្ធ និងចាំបាច់នៃប្រភេទឯកសារ ដើម្បីកាត់បន្ថយបាននូវការយោងឯកសារសំពីងសំពោងច្រើនពេក។ បន្ថែមពីលើនេះ ក៏គិតផងដែរនូវឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត ដែលនេះ នាំឲ្យគេមិនអាចយោងដល់លិខិតបទដ្ឋានដែលមានឋានានុក្រមទាបជាង ឯកសារសេចក្ដីព្រាងដែលយើងកំពុងពិចារណា។ ជាចុងក្រោយ ឯកសារបីប្រភេទ ដែលត្រូវតែយោងមុនគេ។

**ជាយោបល់ផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ មិនតំណាងយោបលស្ថាប័នឡើយ។**